**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ០១៧/២៦ ក.ប/ខ.ល

# សារលិខិតអបអរសាទរ

**សូមគោរពជូន**

**សម្តេចសេដ្ឋវិទូភក្តី គាត ឈន់ ប្រធានកិត្តិយសឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ**

***ជាទីគោរពដ៏ខ្ពង់ខ្ពស់!***

នាឱកាសដ៏មហានក្ខត្តឫក្សប្រកបដោយទឹកចិត្តសោមនស្សរីករាយ តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្នុងនាមខ្ញុំបាទ និងភរិយា ព្រមទាំងក្រុមគ្រួសារ សូមសម្តែងនូវមនោសញ្ចេតនាសប្បាយរីករាយឥតឧបមា និងសូមចូលរួមអបអរសាទរដោយស្មោះអស់ពីដួងចិត្ត ជូនចំពោះ **សម្តេច** ក្នុងឱកាសដែល **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គសព្វព្រះរាជហឫទ័យប្រោសព្រះរាជទានគោរមងារជា **“សម្តេចសេដ្ឋវិទូភក្តី”**។

យើងខ្ញុំសូមសម្តែងនូវការគោរពកោតសរសើរដ៏ស្មោះជូនចំពោះ **សម្តេចសេដ្ឋវិទូភក្តី** ដែលបានបូជានូវកម្លាំងកាយ ចិត្ត និងប្រាជ្ញាស្មារតី ក្នុងបេសកកម្មចូលរួមដឹកនាំ និងអនុវត្តនូវផែនការសកម្មភាពអភិវឌ្ឍន៍ជាតិយ៉ាងសកម្មនាពេលកន្លងមក ជាពិសេស ការចូលរួមចំណែកដឹកនាំពង្រឹងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាតិឱ្យមានការរីកចម្រើន ក្នុងន័យលើកស្ទួយជីវភាពរបស់ប្រជាពលរដ្ឋឱ្យបានល្អប្រសើរ រក្សាបាននូវឯករាជ្យជាតិ បូរណភាពទឹកដី និងជាឧត្តមប្រយោជន៍ជូនជាតិ មាតុភូមិ។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមលើកហត្ថប្រណមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី និងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមជួយអភិបាលប្រោះព្រំសព្វសាធុការពរជ័យគ្រប់ប្រការ ជូន **សម្តេចសេដ្ឋវិទូភក្តី** ព្រមទាំងក្រុមគ្រួសារ សូមសមប្រកបដោយព្រះពុទ្ធពរបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចសេដ្ឋវិទូភក្តី គាត ឈន់ ប្រធានកិត្តិយសឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ** មេត្តាទទួលនូវគារវកិច្ចដ៏ស្មោះស្ម័គ្រពីយើងខ្ញុំ។/.

ថ្ងៃ អង្គារ ១៤កើត ខែ ផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែមីនា ឆ្នាំ២០២៦

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**ហេង សួរ**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩